# សេចក្ដីជូនដំណឹង
## ស្ដីពី
## កាលបរិច្ឆេទកំណត់ទុក សម្រាប់ការបែងចែកភាគលាភប្រចាំឆ្នាំ២០២១ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

**ធនាគារ អេស៊ីលីដា ភីអិលស៊ី** (“ធនាគារ អេស៊ីលីដា”) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជនទាំងអស់ មេត្តាជ្រាបថា ដោយអនុលោមតាមសេចក្ដីសម្រេច នៃកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញលើកទី២២ របស់ធនាគារ អេស៊ីលីដា នាថ្ងៃទី២ ខែឧសភា ឆ្នាំ២០២២ ភាគហ៊ុនិកបានអនុម័តការបែងចែកភាគលាភជាសាច់ប្រាក់ចំនួន៣៥% នៃប្រាក់ចំណេញក្នុងការិយបរិច្ឆេទ ដែលផ្ដល់ជូនដល់ភាគហ៊ុនិករបស់ធនាគារ អេស៊ីលីដា ចំនួន៦៧៩.០០២.២៤០.០០០រៀល ស្មើនឹង ២៣៧.៦៥០.៧៧៥.៣២៥,៦៧រៀល ក្នុងអត្រា៥៤៨,៦៤០៥រៀល ក្នុង១ភាគហ៊ុន និងរក្សាប្រាក់ចំណេញនៅសល់ក្នុងខ្ទង់ប្រាក់ចំណេញរក្សាទុករបស់ធនាគារ អេស៊ីលីដា ដែល**នឹងត្រូវអនុម័តចុងក្រោយដោយនិយ័តករ**។ ចំពោះកាលបរិច្ឆេទកំណត់ទុកសម្រាប់ប្រកាសបញ្ជីឈ្មោះភាគហ៊ុនិក ដែលត្រូវទទួលបានភាគលាភ គឺនៅ**ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២២**។

**សម្គាល់៖**

១. ភាគហ៊ុនិកដែល**លក់**មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) របស់ខ្លួននៅ**ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២២** នឹង**នៅតែមាន**សិទ្ធិទទួលបានភាគលាភនេះដដែល;

២. ភាគហ៊ុនិកដែល**ទិញ**មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) របស់ខ្លួននៅ**ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២២** នឹង**មិនមាន**សិទ្ធិទទួលបានភាគលាភនេះទេ; និង

៣. ភាគលាភនេះនឹងត្រូវបែងចែកជូនភាគហ៊ុនិក បន្ទាប់ពីទទួលបានការអនុម័តពីនិយ័តករ (ធនាគារជាតិនៃកម្ពុជា)។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ៤កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២២

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**

ធនាគារ អេស៊ីលីដា ភីអិលស៊ី
ACLEDA BANK PLC.

ចុះបញ្ជីក្រោមលេខ
Registration No. 00003077

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
#61, Preah Monivong Blvd., Sangkat Srah Chork, Khan Daun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: +855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box: 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP